**សលាកប័ត្រព័ត៌មាន៖** ការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិនៅកម្ពុជា

**ខ្លឹមសារសង្ខេប៖** រាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") មានកាតព្វកិច្ចត្រូវគោរពបទដ្ឋានមួយចំនួនអនុលោមតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ រដ្ឋាភិបាលត្រូវតែអនុវត្តតាមគោលការណ៍ ជូស យូហ្សិន្ទ (**Jus Cogens**) និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយកាតព្វកិច្ចនេះត្រូវបានចងភ្ជាប់ដោយសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ដែលខ្លួនបានផ្តល់សច្ចាប័ន។

**សេចក្តីផ្តើម**

សលាកប័ត្រព័ត៌មាននេះ ផ្តល់នូវទិដ្ឋភាពរួមនៃការអនុវត្តបទដ្ឋានដែលជាប្រភពសំខាន់ៗនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិនៅក្នុងប្រព័ន្ធច្បាប់របស់កម្ពុជា។ សលាកប័ត្រព័ត៌មាននេះ គឺតាក់តែងឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងប្រទេសកម្ពុជា។

**គោលការណ៍ ជូស យូហ្សិន្ទ (Jus Cogens) និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ**

គោលការណ៍ជូស យូហ្សិន្ទ (**Jus Cogens**) គឺជាគោលការណ៍មូលដ្ឋាននៃច្បាប់អន្តរជាតិ ដែលត្រូវបានទទួលស្គាល់ជាគោលការណ៍ចាំបាច់ត្រូវតែគោរពតាម ដោយមិនត្រូវបំពាន ទោះក្នុងកាលៈទេសៈណាក៏ដោយ។ គោលការណ៍ជូស យូហ្សិន្ទ (**Jus Cogens**) បង្កើតបានជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយត្រូវបានបញ្ញត្តក្នុងមាត្រា ៥៣ នៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា ឆ្នាំ១៩៦៩។ ពុំមានបញ្ជីអំពីគោលការណ៍ច្បាប់អន្តរជាតិច្បាស់លាស់ដែលបញ្ជាក់ពីចំនួននៃគោលការណ៍ជូស យូហ្សិន្ទ (**Jus Cogens**) នេះទេ ប៉ុន្តែគោលការណ៍នេះត្រូវបានទទួលស្គាល់ជាទូទៅថា ជាគោលការណ៍រួមបញ្ចូលទាំងការហាមឃាត់អំពើប្រល័យពូជសាសន៍ និងការធ្វើទារុណកម្ម។

ច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រូវបានកំណត់ថាជា "ការអនុវត្តជាទូទៅដែលត្រូវបានទទួលស្គាល់ដូចជាច្បាប់" របស់រដ្ឋនានាផងដែរ។ ដើម្បីទទួលបានឋានៈជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចាំបាច់ត្រូវការការអនុវត្តរបស់រដ្ឋ ដែលកើតមានជាទូទៅ ដែលមានភាពស៊ីសង្វាក់ និងការព្រមព្រៀងគ្នា ហើយនិងគោលការណ៍អូពីយ៉ាណូជូរីស្ហ (*opinio juris*)(ជំនឿដែលថា សកម្មភាពណាមួយត្រូវបានប្រព្រឹត្តទៅ ដោយសារតែវាជាកាតព្វកិច្ចតាមផ្លូវច្បាប់)។ ច្បាប់ទំនៀមទម្លាប់អន្តរជាតិចងរដ្ឋទាំងអស់ រួមទាំងរដ្ឋទាំងឡាយណាដែលមិនមែនជាភាគីនៃសន្ធិសញ្ញា។ ឧទាហរណ៍ គោលការណ៍នានាដែលមាននៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស("ស.ស.ស.ម") ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថាជាវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយមិនតម្រូវឲ្យមានការចុះហត្ថលេខា ឬការផ្តល់សច្ចាប័នពីរដ្ឋ ដែលត្រូវទទួលស្គាល់ថាបទដ្ឋានតាមផ្លូវច្បាប់នោះទេ។

**សន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស**

តាមរយៈការក្លាយទៅជាបណ្ដារដ្ឋភាគីរបស់សន្ធិសញ្ញាអន្តរជាតិ (ឧទាហរណ៍ ការផ្ដល់សច្ចាប័ន) រដ្ឋត្រូវសន្មតថាខ្លួនមានកាតព្វកិច្ច និងភារកិច្ចតាមច្បាប់អន្តរជាតិក្នុងការគោរព ការពារ និងអនុវត្តគោលការណ៍សិទ្ធិមនុស្ស។ នៅប្រទេសកម្ពុជា ដរាបណាកម្ពុជាបានចុះហត្ថលេខាលើសន្ធិសញ្ញាណាមួយ សន្ធិសញ្ញានោះត្រូវដាក់ស្នើទៅរដ្ឋសភាដើម្បីអនុម័ត បន្ទាប់មកបញ្ជូនទៅព្រឹទ្ធសភា មុនពេលត្រូវប្រកាសឲ្យប្រើដោយព្រះមហាក្សត្រ។ ក្រោយមក សន្ធិសញ្ញាអន្តរជាតិនឹងត្រូវចងកាតព្វកិច្ចតាមច្បាប់ជាតិ និងអាចត្រូវបានលើកយកមកសម្អាងដោយតុលាការកម្ពុជា។

រដ្ឋាភិបាលបានក្លាយជារដ្ឋហត្ថលេខីនៃសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្សសំខាន់ៗដូចខាងក្រោម៖

- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌ ឆ្នាំ១៩៦៦ (ចូលជាធរមាននៅឆ្នាំ១៩៩២)
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦ (ចូលជាធរមាននៅឆ្នាំ១៩៩២)
- អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងអំពើឃោរឃៅ អមនុស្សធម៌ ឬការប្រព្រឹត្ត ឬការដាក់ទណ្ឌកម្មបន្ទាបតម្លៃជាមនុស្ស ឆ្នាំ១៩៨៤ (ចូលជាធរមាននៅឆ្នាំ១៩៩២)
- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី ឆ្នាំ១៩៧៩ (ចូលជាធរមាននៅឆ្នាំ១៩៩២)
- អនុសញ្ញាស្តីពីសិទ្ធិកុមារ ឆ្នាំ១៩៨៩ (ចូលជាធរមាននៅឆ្នាំ១៩៩២)
- អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងជាតិសាសន៍ ឆ្នាំ១៩៦៥ (ចូលជាធរមាននៅឆ្នាំ១៩៩៣)
- អនុសញ្ញាស្តីពីសិទ្ធិរបស់ជនពិការ ឆ្នាំ២០០៦ (ចូលជាធរមាននៅឆ្នាំ២០១២)
- អនុសញ្ញាអន្តរជាតិស្តីពីការការពារបុគ្គលគ្រប់ពីការបាត់ខ្លួនដោយបង្ខំ ឆ្នាំ២០០៦ (ចូលជាធរមាននៅឆ្នាំ២០១៣)។

កម្ពុជាក៏បានចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ ឆ្នាំ១៩៩០ កាលពីឆ្នាំ២០០៤ ប៉ុន្តែនៅមិនទាន់បានផ្តល់សច្ចាប័ននៅឡើយទេ។ ទោះជាយ៉ាងនេះក្តី ការចុះហត្ថលេខាលើសន្ធិសញ្ញា បង្ហាញពីចេតនារបស់រដ្ឋាភិបាលក្នុងការផ្តល់សច្ចាប័ននៅពេលឆាប់ៗខាងមុខ។ ហេតុដូច្នេះ កម្ពុជាត្រូវបានជាប់កាតព្វកិច្ចមិនត្រូវធ្វើអ្វីដែលបណ្តាលឲ្យប៉ះពាល់ ឬអន្តរាយដល់កម្មវត្ថុ និងគោលបំណងរបស់សន្ធិសញ្ញាឡើយ។ សូមចុចលើគេហទំព័រនេះ ដើម្បីស្វែងរកសន្ធិសញ្ញា និងអនុសញ្ញាទាំងឡាយដែលត្រូវបានផ្តល់សច្ចាប័ន ឬទទួលស្គាល់ដោយកម្ពុជា។

**ការអនុវត្តសន្ធិសញ្ញាស្តីពីសិទ្ធិមនុស្សដោយផ្ទាល់នៅកម្ពុជា**

យោងតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") កម្ពុជាទទួលស្គាល់ និងគោរពសន្ធិសញ្ញាអន្តរជាតិទាំងឡាយទាក់ទិននឹងសិទ្ធិមនុស្ស ថាជាផ្នែកមួយនៃច្បាប់ជាតិ។ សេចក្តីសម្រេចរបស់

ក្រុមប្រឹក្សាធម្មនុញ្ញចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ បានបញ្ជាក់បន្ថែមពីការអនុវត្តសន្ធិសញ្ញាអន្តរជាតិស្ដីពីសិទ្ធិមនុស្សដោយតុលាការកម្ពុជា។ ចៅក្រមត្រូវមានកាតព្វកិច្ចពិចារណាច្បាប់ជាតិទាំងអស់ នៅពេលបកស្រាយច្បាប់ និងធ្វើសេចក្ដីសម្រេចចិត្ត *"រួមទាំងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល ច្បាប់ទាំងឡាយដែលមានអានុភាពអនុវត្ត និងច្បាប់អន្តរជាតិទាំងឡាយដែលត្រូវបានទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជាផង [...]"*។ សេចក្ដីសម្រេចបែបនេះបញ្ជាក់ថា សន្ធិសញ្ញាអន្តរជាតិស្ដីពីសិទ្ធិមនុស្សដែលកម្ពុជាបានផ្ដល់សច្ចាប័នរួចហើយ អាចអនុវត្តបានដោយផ្ទាល់នៅក្នុងប្រព័ន្ធច្បាប់របស់កម្ពុជា។

**សេចក្ដីសន្និដ្ឋាន/អនុសាសន៍**

រដ្ឋាភិបាលកម្ពុជាត្រូវអនុវត្តតាមគោលការណ៍អន្តរជាតិនៃជូស យូហ្សិន្ទ (**Jus Cogens**) និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ព្រមទាំងត្រូវការពារ លើកកម្ពស់ និងអនុវត្តកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួន ដូចដែលមានកំណត់នៅក្នុងសន្ធិសញ្ញា និងអនុសញ្ញាទាំងឡាយដែលខ្លួនបានផ្ដល់សច្ចាប័ន។ សរុបទៅ កម្ពុជាបានបញ្ចូលបទប្បញ្ញត្តិមួយចំនួននៃសន្ធិសញ្ញាស្ដីពីសិទ្ធិមនុស្សទៅក្នុងច្បាប់ជាតិ។ ទោះជាយ៉ាងនេះក្ដី បទប្បញ្ញត្តិខ្លះនៃច្បាប់កម្ពុជានៅមានភាពស្រពេចស្រពិល និងមានចន្លោះប្រហោងជាច្រើន ដែលបញ្ហានេះធ្វើឲ្យអន់ថយ ឬរឹតត្បិតកាតព្វកិច្ចសិទ្ធិមនុស្សរបស់កម្ពុជា។ ឧទាហរណ៍ មាត្រា ៥០២ នៃក្រមព្រហ្មទណ្ឌកំណត់ពីបទល្មើសព្រហ្មទណ្ឌពាក់ព័ន្ធនឹងបទប្រមាថប្រឆាំងនឹងអ្នករាជការសាធារណៈ ដែលបំពេញមុខងារនៅក្នុងនាមស្ថាប័នរបស់ខ្លួន និងមាត្រា ៥២៣ បញ្ញត្តពីបទធ្វើឲ្យបាត់បង់ជំនឿចិត្តលើសេចក្ដីសម្រេចរបស់តុលាការ។ បទប្បញ្ញត្តិទាំងពីរនេះរឹតត្បិតដល់សិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងមិនស្របទៅនឹងកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជាឡើយ។ មាត្រា ២ នៃច្បាប់ស្ដីពីបាតុកម្មដោយសន្តិវិធី ក៏បានកំណត់ថា ការជួបប្រជុំដោយសន្តិវិធី *"មិនត្រូវឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាព និងកិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គមជាតិ ដល់សណ្ដាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិឡើយ។"* ការរឹតត្បិតទាំងនេះ និងជាពិសេស"កិត្តិយសរបស់អ្នកដទៃ" និង "ទំនៀមទម្លាប់ល្អរបស់សង្គមជាតិ" ធ្វើឲ្យមានការរឹតត្បិតយ៉ាងទូលំទូលាយដ៏ច្បាស់លាស់លើសិទ្ធិសេរីភាពខាងការជួបប្រជុំ ហើយហេតុដូច្នេះ មិនស្របទៅនឹងការកំណត់នៅក្នុងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ រដ្ឋាភិបាលត្រូវតែគោរពតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួន និងមិនអាចប្រើប្រាស់ច្បាប់ជាតិជាមធ្យោបាយដើម្បីគេចវេសពីកាតព្វកិច្ចនេះទេ។ ហេតុដូចនេះ ការអនុវត្តដោយផ្ទាល់ និងការលើកយកមកជាសម្អាងជាទូទៅចំពោះបទប្បញ្ញត្តិស្ដីពីសិទ្ធិមនុស្សផ្សេងៗ គឺជាការចាំបាច់ និងត្រូវបានលើកទឹកចិត្ត។ ម.ស.ម.ក សូមអំពាវនាវដល់រដ្ឋាភិបាលឲ្យធ្វើវិសោធនកម្មបទប្បញ្ញត្តិមួយចំនួននៃច្បាប់ជាតិ ដើម្បីធានាថាច្បាប់ជាតិអនុវត្តស្របតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជា។

**សម្រាប់ព័ត៌មានលម្អិត សូមទាក់ទង លោក ឌុច ពិសិដ្ឋ តាមរយៈទូរសព្ទ៖ +៨៥៥(០) ១២ ៧១ ២៣ ៧១ ឬអ៊ីម៉ែល៖ duchpiseth@cchrcambodia.org ឬលោកស្រី អេលីស ទីឡែត តាមរយៈទូរសព្ទ៖ +៨៥៥ (០) ៧៧ ៧០ ៩៧ ២៣ ឬអ៊ីម៉ែល៖ elise.tillet@cchrcambodia.org។**

CC BY NC SA